**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

លេខ ៧៩ វប.ក

# ប្រ កា ស

## ស្តីពី

## ការពង្រឹងការងារគ្រប់គ្រងសិល្បៈសូនរូប និងសិប្បកម្ម

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យ លេខ៦២ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមសេចក្តីត្រូវការចាំបាច់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## ស ម្រេ ច

**ប្រការ១.-**

សិល្បៈសូនរូប និងសិប្បកម្ម គឺជាការបង្កើតជារូប ឬវត្ថុសិល្បៈដែលមានទម្រង់ផ្សេងៗដូចជា : គំនូរ ចម្លាក់ តម្បាញ សិល្បៈរូបថត ដេរ ចាក់ ខ្វក់ ស្មាច់ កុលាលភាជន៍ ស្ថាបត្យកម្ម តុបតែងលំអ Video Art សិល្បៈកញ្ចក់...។

ប្រការ២._

និតិបុគ្គល ឬរូបវន្តបុគ្គលដែលមានបំណងបើកកន្លែងផលិតវត្ថុសិល្បៈ ដើម្បីធ្វើអាជីវកម្មត្រូវឆ្លងកាត់ការត្រួតពិនិត្យបច្ចេកទេសជំនាញ និងត្រូវមានអាជ្ញាប័ណ្ណអនុញ្ញាតពីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង ។

ប្រការ៣._

និតិបុគ្គល ឬរូបវន្តបុគ្គលដែលមានបំណងធ្វើអាជីវកម្មទិញលក់វត្ថុសិល្បៈ ត្រូវមានអាជ្ញាប័ណ្ណអនុញ្ញាតពីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង ។

ប្រការ៤._

សិល្បករ សិប្បករ ឬអាជីវករ ដែលកំពុងប្រកបមុខរបរផលិត ឬទិញលក់វត្ថុសិល្បៈគ្រប់ប្រភេទដែលពុំមានអាជ្ញាប័ណ្ណ ឬអាជ្ញាប័ណ្ណផុតកំណត់ត្រូវរៀបចំសំណុំបែបបទសុំអាជ្ញាប័ណ្ណជាថ្មីពីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តក្រុង ។

ប្រការ៥._

ការនាំចេញនូវវត្ថុសិល្បៈទៅក្រៅប្រទេស ត្រូវមានទិដ្ឋាការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

ប្រការ៦._

ការផលិតវត្ថុសិល្បៈគ្រប់ប្រភេទក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់បង្ហាញសញ្ញា " កម្ពុជា CAMBODIA " ឈ្មោះ និងទីតាំងជាសំគាល់ ។

វត្ថុសិល្បៈទាំងឡាយណា ដែលបាននាំចូលក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានសញ្ញាសំគាល់ប្រទេសដែលបានផលិត ។

ប្រការ៧._

ការផលិត ឬដាក់តាំងលក់វត្ថុសិល្បៈដែលពុំត្រឹមត្រូវតាមរចនាប័ទ្ម ឬពុំគោរពតាមលក្ខណៈខ្នាតសិល្បៈជាតិត្រូវហាមឃាត់ ។

ប្រការ៨._

ការយកវត្ថុបុរាណមកតាំងលាយឡំជាមួយវត្ថុសិល្បៈ ឬវត្ថុអនុស្សាវរីយ៍ត្រូវហាមឃាត់ ។

ប្រការ៩._

ទីតាំងលក់វត្ថុសិល្បៈ ត្រូវមានការរៀបចំឱ្យបានសមរម្យតាមក្បួនខ្នាតដែលបានកំណត់ជូន ជៀសវាងការដាក់ផ្ទាល់ដី ។

**ប្រការ១០.-**

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង សហការជាមួយស្ថាប័នមានសមត្ថកិច្ច និងអាជ្ញាធរដែនដី មានសិទ្ធិដកអាជ្ញាប័ណ្ណ ឬបញ្ឈប់ការផលិត ឬទិញលក់វត្ថុសិល្បៈ ចំពោះសិប្បករ ឬអាជីវករណាដែលប្រព្រឹត្តផ្ទុយពីខ្លឹមសារនៃប្រកាសនេះ ។

**ប្រការ១១.-**

ខុទ្ទកាល័យរដ្ឋមន្ត្រី អធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ សាកលវិទ្យាល័យភូមិន្ទ និងវិចិត្រសិល្បៈ គ្រប់នាយកដ្ឋានក្រោមឱវាទ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង មានភារកិច្ចអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាពភាពខ្ពស់ ចាប់ពីថ្ងៃឡាយព្រះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ . ថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០០៥

ព្រះរាជាណាចក្រកម្ពុជា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ-បញ្ញាសារ៉ា ស៊ីសុវត្ថិ

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ